ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តសៀមរាប**

- សំណុំរឿងព្រហ្មទណ្ឌលេខ ០៣

ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០២២

- សំណុំរឿងជំនុំជម្រះលេខ ២៤៨

ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២

- សាលក្រមព្រហ្មទណ្ឌលេខ ២៨"ឃ"/ ៣៨៤

ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តសៀមរាប

បើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តសៀមរាបនាសាលសវនាការលេខៈ០២។

កាលបរិច្ឆេទបើកសវនាការនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ៨ និង ៣០ នាទីព្រឹក។

កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ៣ និង ៣០នាទីរសៀល។

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប

លោក [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប

### តំណាងអយ្យការ

លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខប៉ាវ។

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] អ៊ីត។

ដើម្បីជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌលេខៈ ០៣ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] សុខប៉ាវ ហៅ ឌី ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិខ្មែរ មុខរបរ កម្មករ ទីកន្លែងកំណើត នៅភូ[redacted] ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្នភូមិជីមាស ឃុំម្យាក្រង ស្រុកស្ទោង

ខេត្តកំពង់ធំ កម្រិតវប្បធម៌ថ្នាក់ទី០៤ នៅលីវ ឪពុកឈ្មោះ [redacted] ពឿន (ស) ម្តាយឈ្មោះ [redacted] ឡា (រ) ទោសពីមុន គ្មាន។ (ក្នុងឃុំ)

២.ឈ្មោះ [redacted] អ៊ីត ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត នៅភូមិ [redacted] ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្នភូមិជីមាស ឃុំម្សាក្រង ស្រុកស្ទោង ខេត្តកំពង់ធំ កម្រិតវប្បធម៌ថ្នាក់ទី០៧ នៅលីវ ឪពុកឈ្មោះ [redacted] អ៊ីម (ស) ម្តាយឈ្មោះ [redacted] ថាញ (រ) ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារ។ (ក្នុងឃុំ)

ជាប់ចោទពីបទ៖ **ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោស (ឆក់កាបូបបណ្តាលឱ្យរងរបួស)** ប្រព្រឹត្តនៅចំណុចផ្លូវ៦០ម៉ែត្រ ភូមិគោកចាន់ ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២៧** មាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធារី ភេទស្រី អាយុ ៣១ឆ្នាំ អាសយដ្ឋានភូមិត្រពាំងរុន ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ (ទាមទារសំណងជម្ងឺចិត្តចំនួន ១០.០០០.០០០រៀល)

-តាមដីកាសន្និដ្ឋានស្ថាពរលេខ : ៨៥ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ។

-តាមដីកាដំណោះស្រាយលេខ : ៩៧៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ : ៣០២ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

## <u>៦អង្គហេតុកើតមានដូចតទៅ</u>

កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ១៧ និង៣០នាទី មានមនុស្ស ០២នាក់ ម្នាក់ឈ្មោះ [redacted] សុខប៉ាវ ភេទប្រុស អាយុ ២២ឆ្នាំ និងម្នាក់ទៀតឈ្មោះ [redacted] អ៊ីត ភេទប្រុស អាយុ ២០ឆ្នាំ បានជិះម៉ូតូម៉ាកហុងដាឌ្រីមស៊េរីឆ្នាំ២០២០ ពណ៌ខ្មៅ មកពីខេត្តកំពង់ធំ រស់នៅភូមិជីមាស ឃុំម្សាក្រង ស្រុកស្ទោង ខេត្តកំពង់ធំ បានមកដើរលេងឆ្លងឆ្នាំនៅខេត្តសៀមរាប ហើយបានធ្វើសកម្មភាពឆក់កាបូបរបស់ឈ្មោះ [redacted] ធារី ដែលជានារីមានផ្ទៃពោះ ដែលកំពុងតែបើកបរឌុបកូនប្រុសម្នាក់អាយុ ០២ឆ្នាំ នៅតាមបណ្តោយផ្លូវ ៦០ម៉ែត្រ ស្ថិតនៅភូមិគោកចាន់ ឃុំអំពិលស្រុកប្រាសាទបាគង ខេត្តសៀមរាប បណ្តាលឱ្យដួលម៉ូតូរងរបួសទាំងពីរនាក់ ម្តាយនិងកូន ហើយម៉ូតូរបស់ជនសង្ស័យនោះក៏បានដួលដែរ ដោយម្នាក់ឈ្មោះ [redacted] សុខប៉ាវ បានធ្លាក់ចូលទៅក្នុងទឹក និងម្នាក់ទៀតឈ្មោះ [redacted] អ៊ីត បានលើកម៉ូតូជិះរត់គេចខ្លួន។ ឈ្មោះ [redacted] សុខប៉ាវ បានឡើងមកសំពះជនរងគ្រោះ ហើយក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន និងបានធ្វើតេស្តស្វែងរកសារធាតុញៀន ជាលទ្ធផលវិជ្ជមានរួចបញ្ជូនមកចាត់ការតាមនីតិវិធី។ ចំណែកឯឈ្មោះ [redacted] អ៊ីត ត្រូវបានសមត្ថកិច្ចចាប់ខ្លួនបាននៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០២២។



Scanned with CamScanner

# នាពេលសវនាការ

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] អ៊ីត បានឆ្លើយថា៖ ខ្លួនទទួលស្គាល់ថា ខ្លួនពិតជាបានឆក់កាបូបគេប្រាកដមែន គឺឆក់នៅម្តុំផ្លូវ៦០ម៉ែត្រ ព្រោះតែពេលនោះខ្លួន និងមិត្តភក្តិអត់លុយចាក់សាំងម៉ូតូត្រឡប់ទៅផ្ទះវិញ។ កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោងប្រហែលម៉ោង ១១ព្រឹក ខ្លួនបានជិះម៉ូតូម៉ាកហុងដាឌ្រីមសេរីឆ្នាំ២០២០ ដែលបានខ្ចីពីពូរបស់ខ្លួន ពីខេត្តកំពង់ធំ មកលេងឆ្លងឆ្នាំនៅខេត្តសៀមរាប ដោយមានគ្នាចំនួន ០៦នាក់ មានម៉ូតូ ០៣គ្រឿង ពេលនោះខ្លួនបានឌុបមិត្តភក្តិរបស់ខ្លួនឈ្មោះ [redacted] សុខប៉ាវ ហៅ ឌី។ រហូតដល់ម៉ោង៤រសៀល ទើបពួកខ្លួនមកដល់ខេត្តសៀមរាប។ មកដើរលេងនេះខ្លួនមិនមានលុយទេ តែពួកម៉ាករបស់ខ្លួនឈ្មោះ ឌី ប្រាប់ថាគេមានលុយ តែពេលមកដល់ខេត្តសៀមរាបឈ្មោះ ឌី គេថាគេអស់លុយហើយ ហើយពួកម៉ាកខ្លួន០៤នាក់ទៀត ក៏បាននិយាយថា ចាំគេប៉ាវហូបអី។ រួចហើយពួកខ្លួនក៏បាននាំគ្នាជិះម៉ូតូមកហូបអីនៅផ្លូវ៦០ម៉ែត្រ តែពេលទៅដល់ ពួកម៉ាករបស់ខ្លួន ២ម៉ូតូ ដែលមានគ្នា ០៤នាក់ នោះប្រាប់ឱ្យខ្លួន និងឈ្មោះ ឌី នៅចាំគេសិន គេទៅនោះមួយភ្លែត តែខ្លួនមិនបានដឹងថាគេទៅណានោះទេ។ ពេលចាំគេយូរពេក ពួកម៉ាកខ្លួនឈ្មោះ ឌី ក៏បានខលទៅ ០៤នាក់ នោះ តែពួកគេមិនបានលើកទូរស័ព្ទនោះទេ។ បន្ទាប់មកខ្លួន និងពួកម៉ាកឈ្មោះ ឌី ក៏បាននាំគ្នាបបួលគ្នាជិះម៉ូតូត្រឡប់ទៅផ្ទះនៅខេត្តកំពង់ធំវិញទាំងយប់។ វេលាម៉ោងប្រហែល ៦ និង៣០នាទីយប់ ពេលដែលខ្លួន និងពួកម៉ាកខ្លួនឈ្មោះ ឌី កំពុងតែជិះម៉ូតូត្រឡប់ទៅផ្ទះវិញ ក៏បានប្រទះឃើញមនុស្សស្រីម្នាក់កំពុងតែជិះម៉ូតូឌុបកូននៅតាមដងផ្លូវ ដោយមានស្ពាយកាបូបចំហៀងឆៀងមកផ្នែកខាងស្តាំ រួចហើយខ្លួន និងពួកម៉ាកឈ្មោះ ឌី ក៏បាននាំគ្នាបបួលគ្នាឆក់កាបូបគេតែម្តង ព្រោះថាពេលនោះពួកខ្លួនអត់លុយចាក់សាំងម៉ូតូជិះត្រឡប់ទៅផ្ទះវិញ។ ពេលដែលពួកខ្លួនចាប់ផ្តើមធ្វើសកម្មភាពឆក់កាបូបគេ ពេលនោះខ្លួនជាអ្នកបើកម៉ូតូឌុបឈ្មោះ ឌី ហើយក៏ជាអ្នកឆក់កាបូបគេដែរ ហើយឈ្មោះ ឌី ជាអ្នកមើលផ្លូវឱ្យ។ ពេលនោះគឺឆក់មិនបាននោះទេ ព្រោះពេលដែលធ្វើសកម្មភាពឆក់គឺពួកខ្លួនដួលម៉ូតូ ហើយអ្នកដែលត្រូវបានខ្លួនឆក់នោះក៏បានដួលម៉ូតូដូចគ្នា។ ភ្លាមនោះមិត្តភក្តិរបស់ខ្លួនឈ្មោះ ឌី ក៏បានរត់គេចខ្លួន ហើយខ្លួនក៏បានបើកម៉ូតូរត់គេចខ្លួនផងដែរ។ ពេលដែលខ្លួនកំពុងតែជិះម៉ូតូរត់គេច ម៉ូតូរបស់ខ្លួនក៏អស់សាំង គឺអស់នៅម្តុំកន្លែងលក់ក្រឡាន បន្ទាប់មកខ្លួនក៏បានបញ្ចាំទូរស័ព្ទរបស់ខ្លួនម៉ាក Iphone6 ចំនួន ១០,០០០(មួយម៉ឺន)រៀល ជាមួយនឹងអ្នកលក់ក្រឡាន ដើម្បីចាក់សាំងម៉ូតូ ជិះម៉ូតូមកផ្ទះ។ រហូតដល់វេលាម៉ោង ៣រសៀល សមត្ថកិច្ចក៏បានឃាត់ខ្លួននៅផ្ទះរបស់ខ្លួន ដែលមានទីតាំងស្ថិតនៅភូមិជីមាស ឃុំម្សាក្រង ស្រុកស្ទោង ខេត្តកំពង់ធំ ពេលនោះខ្លួនកំពុងតែរៀបអីវ៉ាន់ជួយលក់ម្តាយ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខប៉ាវ ហៅ ឌី បានឆ្លើយថា៖ កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោងប្រហែល ៧យប់ ខ្លួនបានជិះម៉ូតូ ០២នាក់ មិត្តភ័ក្រ្តឈ្មោះ[redacted] អ៊ីត ទិសដៅពីកើតទៅលិច ដោយឈ្មោះ[redacted] អ៊ីត ជាអ្នកឌុបខ្លួន នៅតាមបណ្តោយផ្លូវ ៦០ម៉ែត្រ។ ពេលកំពុងជិះម៉ូតូឈ្មោះ [redacted]អ៊ីត បានសួរខ្លួនថា ហ៊ានឆក់កាបូបអត់ ហើយខ្លួនក៏បានឆ្លើយថា អត់ឆក់ទេ និងប្រាប់វាកុំឱ្យឆក់កាបូបគេ ស្រាប់តែពេលនោះឈ្មោះ[redacted]អ៊ីត បានឆក់កាបូប (ស្ពាយចំហៀង) ពីជនរងគ្រោះជាមនុស្សស្រីកំពុងជិះម៉ូតូឌុបកូនម្នាក់បណ្តាលឱ្យដួលម៉ូតូ ហើយជនរងគ្រោះរបួសស្រាល ចំណែកម៉ូតូរបស់ខ្លួនក៏ដួលដូចគ្នា។ ពេលដួលម៉ូតូហើយខ្លួនបានរត់ចូលក្នុងប្រឡាយទឹកចំណែកឈ្មោះ [redacted] អ៊ីត បានលើកម៉ូតូជិះទៅបាត់ ក្រោយមកខ្លួនក៏ឡើងពីទឹកទៅសុំទោសជនរងគ្រោះបន្ទាប់មកប៉ូលីសក៏មកដល់ហើយចាប់ឃាត់ខ្លួនតែម្តង។

-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ធារី បានឆ្លើយថា៖ កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោងប្រហែល ១រសៀល ខ្លួនបានឌុបកូនប្រុស ០១នាក់ ឈ្មោះ [redacted]ចិត្រ អាយុ ២ឆ្នាំ ទៅលេងផ្ទះម្តាយនៅភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ខ្លួនក៏ត្រូវបានចោរឆក់កាបូបតែម្តង។ ពេលដែល

ខ្លួនជិះម៉ូតូ ខ្លួនបានស្ពាយកាបូបដាក់លុយ ដោយស្ពាយចំហៀងឆៀងមកខាងស្តាំ ហើយក៏ត្រូវបានមនុស្សប្រុស ០២នាក់ ជិះមកឆក់កាបូបខ្លួនតែម្តង តែពួកគេឆក់មិនបាននោះទេ គឺគ្រាន់តែដួលម៉ូតូ។ ម៉ូតូរបស់ ខ្លួនក៏ដួលដែរ ហើយខ្លួន និងកូនរងរបួស ដោយដាច់រលាតស្បែកហូរឈាម និងកូនប្រុសដាច់រលាតផ្នែកក្បាល និងមានឈាម ហូរចេញតាមត្រចៀក ហើយត្រូវបានប្តីមកជួយ និងជូនទៅមន្ទីរពេទ្យតែម្តង។ បច្ចុប្បន្នខ្លួនមានទម្ងន់កូនក្នុងពោះ ០៧ខែ ហើយកូននៅក្នុងពោះក៏មានការប៉ះពាល់ខ្លះដែរ គឺប៉ះផ្នែកក្បាល ដែលពេទ្យតម្រូវឱ្យតាម ដានមើលបន្ត ដោយឡែកចោរទាំងពីរនាក់ដែលបានឆក់ខ្លួននោះ ពេលនោះមានម្នាក់បានជិះម៉ូតូរត់គេចខ្លួន ឯម្នាក់ទៀតមិនបាន រត់ទេ ហើយគេបានចេញមកសុំទោសខ្លួន ហើយថានឹងនាំទៅចាប់ចោរដែលគេចខ្លួននោះ។ ខ្លួនសុំទាមទារជម្ងឺចិត្ត ចំនួន ១០,០០០,០០០ (ដប់លាន)រៀល និងសុំឱ្យផ្តន្ទាទោសជនល្មើសតាមច្បាប់។

**-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា:** ក្រោយពីបានធ្វើការពិភាក្សាដេញដោលក្នុង ពេលសវនាការ រួចមក ឃើញថា ជនជាប់ចោទឈ្មោះ [redacted] **សុខប៉ាវ** បានបដិសេធថាខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ ដូចនេះ តំណាងអយ្យការសុំឱ្យតុលាការពិនិត្យ និងសម្រេចតាមច្បាប់។ ចំពោះឈ្មោះ [redacted] **អ៊ិត** បានសារភាពថា ខ្លួនពិតជាបានប្រព្រឹត្ត ដូចនេះ តំណាងអយ្យការសុំរក្សាបទចោទប្រកាន់ទុកនៅដដែល។

**-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ** [redacted] **សុខប៉ាវ ធ្វើសេចក្តីសន្និដ្ឋាន:** កូនក្តីខ្លួននៅពេលកើត ហេតុ គឺមិនបានប្រព្រឹត្តទេ ដូចនេះស្នើសុំឱ្យតុលាការលើកលែងចោទប្រកាន់មកលើកូនក្តីខ្លួន។

**-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ** [redacted] **អ៊ិត ធ្វើសេចក្តីសន្និដ្ឋាន:** កូនក្តីខ្លួនបានសារភាពទទួល ស្គាល់នូវកំហុសរបស់ខ្លួនដែលបានប្រព្រឹត្ត ដូចនេះស្នើសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សាលាដំបូងខេត្តសៀមរាប

## យល់ឃើញថា

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] អ៊ិត បានឆ្លើយសារភាពថាខ្លួនពិតជាបានប្រព្រឹត្តដូចការចោទ ប្រកាន់មែន គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សុខប៉ាវ** បានឆ្លើយថា ឈ្មោះ [redacted] **អ៊ិត** បានបបួលខ្លួន ឆក់កាបូប ហើយខ្លួនបានប្រាប់គេថាកុំឱ្យឆក់កាបូបគេអី ស្រាប់តែពេលនោះ ឈ្មោះ [redacted] **អ៊ិត** បានឆក់កាបូប (ស្ពាយចំហៀង) ពីជនរងគ្រោះជាមនុស្សស្រីកំពុងជិះម៉ូតូឱបកូនម្នាក់បណ្តាលឱ្យដួលម៉ូតូតែម្តង ហើយឈ្មោះ [redacted] **អ៊ិត** បានលើកម៉ូតូជិះទៅបាត់។ ស្របនឹងចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] **ធារី** ដែលបានឆ្លើយថា នៅថ្ងៃ កើតហេតុមានមនុស្ស ០២នាក់ បានជិះម៉ូតូមកឆក់កាបូបខ្លួន ហើយក៏ដួលទាំងម៉ូតូខ្លួន និងម៉ូតូអ្នកឆក់ ពេលនោះ



Scanned with CamScanner

មានម្នាក់បានជិះម៉ូតូរត់គេចខ្លួន ឯម្នាក់ទៀតមិនបានរត់ទេ ហើយគេបានចេញមកសុំទោសខ្លួន ហើយគេថាគេមិនមែនចោរទេ គឺគ្រាន់តែជិះម៉ូតូជាមួយ ហើយគេនឹងនាំទៅចាប់។ គប្បីតុលាការពិចារណា។

**-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា:** ក្រោយពីបានធ្វើការពិភាក្សាដេញដោលក្នុង ពេលសវនាការរួចមក ឃើញថា ជនជាប់ចោទឈ្មោះ [redacted] **សុខប៉ាវ** បានបដិសេធថាខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ដូចនេះ តំណាងអយ្យការសុំឱ្យតុលាការពិនិត្យ និងសម្រេចតាមច្បាប់។ ចំពោះឈ្មោះ [redacted] អ៊ីត បានសារភាពថាខ្លួនពិតជាបានប្រព្រឹត្ត ដូចនេះ តំណាងអយ្យការសុំរក្សាបទចោទប្រកាន់ទុកនៅដដែល។ គប្បីតុលាការពិចារណា។

**-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខប៉ាវ ធ្វើសេចក្តីសន្និដ្ឋាន:** កូនក្តីខ្លួននៅពេលកើតហេតុគឺមិនបានប្រព្រឹត្តទេ ដូចនេះស្នើសុំឱ្យតុលាការលើកលែងចោទប្រកាន់មកលើកូនក្តីខ្លួន។ គប្បីតុលាការពិចារណា។

**-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] អ៊ីត ធ្វើសេចក្តីសន្និដ្ឋាន:** កូនក្តីខ្លួនបានសារភាពទទួលស្គាល់នូវកំហុសរបស់ខ្លួនដែលបានប្រព្រឹត្ត ដូចនេះស្នើសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង។ គប្បីតុលាការពិចារណា។

-ពុំមានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកទៅលើឈ្មោះ [redacted] **សុខប៉ាវ** ហៅ **នី** ពីបទ **ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោស (ឆក់កាបូបបណ្តាលឱ្យរងរបួស)** គប្បីតុលាការឱ្យរួចផុតពីបទចោទប្រកាន់។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] អ៊ីត ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ,សណ្តាប់ធ្នាប់សាធារណៈជាពិសេសខុសនឹងច្បាប់ព្រហ្មទណ្ឌជាធរមាន។

-ជនជាប់ចោទឈ្មោះ [redacted] អ៊ីត ជាជនដែលអាចយល់ដឹងគ្រប់គ្រាន់ និងមានស្មារតីរឹងមាំអាចដឹងចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ដូច្នេះអាចទទួលការចោទប្រកាន់បាន។

-មានភស្តុតាងគ្រប់គ្រាន់ដើម្បីដាក់បន្ទុកទៅលើជនជាប់ចោទឈ្មោះ [redacted] **អ៊ីត** ពីបទ : **ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោស (ឆក់កាបូបបណ្តាលឱ្យរងរបួស)** ប្រព្រឹត្តនៅចំណុចផ្លូវ៦០ម៉ែត្រ ភូមិគោកចាន់ ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២៧** មាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ធារី** បានទាមទារសំណងជម្ងឺចិត្តចំនួន ១០.០០០.០០០រៀល គប្បីតុលាការពិចារណាតាមស្ថានភាពជាក់ស្តែង។

## សាលាដំបូងខេត្តសៀមរាប
## វិនិច្ឆ័យសេចក្តី

១/-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] អ៊ីត ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៤ឆ្នាំ។

ពីបទ៖ **ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោស (ឆក់កាបូបបណ្តាលឱ្យរងរបួស)** ប្រព្រឹត្តនៅចំណុចផ្លូវ៦០ម៉ែត្រ ភូមិគោកចាន់ ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២៧** មាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

២/-ឲ្យជនជាប់ចោទឈ្មោះ [redacted] សុខប៉ាវ ហៅ ឌី រួចផុតពីបទ ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោស (ឆក់កាបូបបណ្តាលឲ្យរងរបួស) ប្រព្រឹត្តនៅចំណុចផ្លូវ៦០ម៉ែត្រ ភូមិគោកចាន់ ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧ មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៣/-បង្គាប់ឲ្យដោះលែងឈ្មោះ ពឿន សុខប៉ាវ ហៅ ឌី ភេទប្រុស អាយុ ២២ឆ្នាំ (មានសាវតាជាតិដូចខាងលើ)។

៤/-បង្គាប់ឲ្យឈ្មោះ [redacted] អ៊ុត បង់សំណងជម្ងឺចិត្តចំនួន ៤.000.000(បួនលាន)រៀល ឲ្យទៅឈ្មោះ [redacted] ធារី។ ទាមទារលើសពីនេះបដិសេធចោល។

៥/-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ដោយចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធារី និងជនជាប់ចោទឈ្មោះ [redacted] អ៊ុត និងឈ្មោះ [redacted] សុខប៉ាវ ហៅ ឌី ។

ទុកសិទ្ធិឲ្យប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សា**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

សៀមរាប ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានថតចម្លងត្រឹមត្រូវចេញពី

ច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី

សៀមរាប ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner